**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ២៥២ អនក្រ.បក**

## អនុក្រឹត្យ
## ស្តីពី
## ការធ្វើអនុបយោគទីតាំងដីបឹងពោងពាយខាងជើង ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០៧០៨/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៧ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និង នីតិវិធីនៃការធ្វើអនុបយោគទ្រព្យសាធរណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១០១ អនក្រ.បក ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១២ ស្តីពីការកំណត់ផ្ទៃបឹងពោងពាយខាងជើង និង ពោងពាយខាងត្បូង ជាសម្បត្តិសាធារណៈរបស់រដ្ឋ

- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.-**

ត្រូវបានធ្វើអនុបយោគទីតាំងដីបឹងពោងពាយខាងជើង ស្ថិតនៅក្នុងសង្កាត់ភ្នំពេញថ្មី សង្កាត់ឃ្មួញ ខណ្ឌសែនសុខ និងសង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដែលមានផ្ទៃដីទំហំ ១០៨,២៩៦៨ ហិកតា (មួយរយប្រាំបីហិកតា ពីរពាន់ប្រាំបួនរយហុកសិបប្រាំបីម៉ែត្រការ៉េ) ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដើម្បីធ្វើការអភិវឌ្ឍ ដូចមានផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងមាននិយាមកាក្នុងតារាងខាងក្រោម៖

| ល.រ | អាប់ស៊ីស | អ័រដោនេ | ល.រ | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| 1 | 486973 | 1281310 | 28 | 487703.27 | 1282318.13 |
| 2 | 486994 | 1281518 | 29 | 487704.49 | 1282312.18 |
| 3 | 486946 | 1281541 | 30 | 487707.94 | 1282307.23 |
| 4 | 486978 | 1281657 | 31 | 487921.38 | 1282145.94 |
| 5 | 486903 | 1281682 | 32 | 487923.52 | 1281976.95 |
| 6 | 486831 | 1281677 | 33 | 487796.91 | 1281898.94 |
| 7 | 486696 | 1281708 | 34 | 487692.07 | 1281795.67 |
| 8 | 486606 | 1281804 | 35 | 487645.28 | 1281674.64 |
| 9 | 486593 | 1281859 | 36 | 487326.64 | 1281640.67 |
| 10 | 486661 | 1282031 | 37 | 487302.76 | 1281632.81 |
| 11 | 486798 | 1282174 | 38 | 487285.12 | 1281617.14 |
| 12 | 486914 | 1282159 | 39 | 487276.35 | 1281600.72 |
| 13 | 486968 | 1282134 | 40 | 487273.05 | 1281578.36 |
| 14 | 487042 | 1282079 | 41 | 487284.08 | 1281327.6 |
| 15 | 487087 | 1282146 | 42 | 487771.94 | 1283006.13 |
| 16 | 487087 | 1282173 | 43 | 487796 | 1283018 |
| 17 | 487102 | 1282220 | 44 | 487803.3 | 1283016.24 |
| 18 | 487075 | 1282269 | 45 | 487844.08 | 1282972.95 |
| 19 | 487010 | 1282327 | 46 | 487812.27 | 1282941.46 |
| 20 | 487010 | 1282434 | 47 | 487855.27 | 1282901.5 |
| 21 | 487104 | 1282478 | 48 | 487925.2 | 1282971.76 |
| 22 | 487150 | 1282524 | 49 | 488057 | 1282846 |
| 23 | 487224 | 1282676 | 50 | 488050.04 | 1282838.09 |
| 24 | 487382 | 1282795 | 51 | 487994.86 | 1282851.82 |
| 25 | 487648 | 1282945 | 52 | 487957.25 | 1282863.17 |
| 26 | 487701.2 | 1282971.24 | 53 | 487901.37 | 1282882.52 |
| 27 | 487704.56 | 1282965.76 | 54 | 487865.2 | 1282895.89 |

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះ ហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី...២៧... ខែ.....ធ្នូ.........ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ